នស/រកត/១២០១/៤៥០

# ព្រះរាជក្រឹត្យ

## ស្តីពី

## បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស គឺជាកំរៃជីវភាពប្រចាំខែ ដែលរដ្ឋត្រូវផ្តល់ជូនដល់មន្ត្រីរាជការ



Downloaded from http://www.khmerlaws.com

ស្ថិតនៅក្រោមការគ្រប់គ្រង នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ក្នុងការបំពេញការងារ ។

បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស រួមមាន :

- បៀវត្សមូលដ្ឋាន
- ប្រាក់បំណាច់មុខងារ
- ប្រាក់ហានិភ័យ និង ប្រាក់វិភាជន៍គ្រួសារ ។

## ជំពូកទី ១

## បៀវត្សមូលដ្ឋាន

**មាត្រា ២.-**

បៀវត្សមូលដ្ឋាន គឺជាប្រាក់ប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការសំរាប់ជីវភាពរស់នៅ ក្នុងនោះមានៈ គ្រឿងឧបភោគ បរិភោគ ការស្នាក់នៅ សំលៀកបំពាក់ ការព្យាបាលជំងឺ ។ល។

**មាត្រា ៣.-**

បៀវត្សមូលដ្ឋាននៃមន្ត្រីរាជការ ត្រូវបែងចែកទៅតាមប្រភេទ ឋានន្តរស័ក្តិ និងថ្នាក់ដែលត្រូវបានកំណត់ទៅតាមក្រិតនៃសន្ទស្សន៍ដូចខាងក្រោម :

| ប្រ.គ | ឋានន្តរស័ក្តិ | ថ្នាក់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១៤ | ១៣ | ១២ | ១១ | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| ក | ក១ | | | | | | | | | ៤៣៦ | ៤៥៧ | ៤៨២ | ៥០៦ | ៥២៨ | ៥៥០ |
| | ក២ | | | | | ៣៦១ | ៣៧៣ | ៣៨៧ | ៤០២ | ៤១៩ | ៤៣៧ | ៤៥៤ | ៤៦៧ | ៤៧៨ | ៤៨៧ |
| | ក៣ | ៣១៥ | ៣២៣ | ៣៣១ | ៣៤០ | ៣៤៩ | ៣៥៩ | ៣៦៩ | ៣៨០ | ៣៩០ | ៣៩៩ | ៤០៧ | ៤១៤ | ៤២០ | ៤២៥ |
| ខ | ខ១ | | | | | | | | | ៣០៨ | ៣២៤ | ៣៤៤ | ៣៦០ | ៣៧៤ | ៣៨៥ |
| | ខ២ | | | | | ២៥២ | ២៦២ | ២៧២ | ២៨៣ | ២៩៥ | ៣០៦ | ៣១៦ | ៣២៥ | ៣៣៣ | ៣៤០ |
| | ខ៣ | ២២០ | ២២៥ | ២៣០ | ២៣៦ | ២៤៣ | ២៥១ | ២៥៩ | ២៦៦ | ២៧៣ | ២៧៩ | ២៨៤ | ២៨៩ | ២៩៣ | ២៩៧ |
| គ | គ១ | | | | | | | | | ២១២ | ២២៣ | ២៣៥ | ២៤៥ | ២៥៤ | ២៦២ |
| | គ២ | | | | | ១៧៣ | ១៧៨ | ១៨៥ | ១៩៣ | ២០១ | ២០៨ | ២១៥ | ២២២ | ២២៨ | ២៣៣ |
| | គ៣ | ១៥០ | ១៥៤ | ១៥៨ | ១៦៣ | ១៦៨ | ១៧៤ | ១៧៩ | ១៨៤ | ១៨៨ | ១៩២ | ១៩៥ | ១៩៨ | ២០០ | ២០២ |
| | ឃ១ | | | | | | | | | ១៤១ | ១៤៩ | ១៥៧ | ១៦៤ | ១៧០ | ១៧៥ |
| | ឃ២ | | | | | ១១៣ | ១១៧ | ១២២ | ១២៨ | ១៣៤ | ១៣៩ | ១៤៤ | ១៤៨ | ១៥២ | ១៥៥ |

Downloaded from http://www.khmerlaws.com

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឃ | ឃ៣ | ១០០ | ១០២ | ១០៤ | ១០៦ | ១០៩ | ១១២ | ១១៦ | ១២០ | ១២៣ | ១២៦ | ១២៩ | ១៣១ | ១៣៣ | ១៣៥ |

**មាត្រា ៤.-**

តំលៃឯកតានៃសន្ទស្សន៍សំរាប់អនុវត្តក្នុងតារាងបៀវត្សមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មានចំនួន ៣០០ រៀល ។

ការកែប្រែតំលៃឯកតានៃសន្ទស្សន៍នេះ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

មន្ត្រីកម្មសិក្សាដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវបានផ្តល់សន្ទស្សន៍បៀវត្សក្នុងថ្នាក់ទី ១៤ នៃឋានន្តរស័ក្តិទី ៣ របស់ក្របខ័ណ្ឌនីមួយៗ ។ ចំពោះមន្ត្រីដែលជ្រើសរើសចេញពីមន្ត្រីមានក្របខ័ណ្ឌស្រាប់ ត្រូវបានផ្តល់សន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

ក្នុងរយៈពេលកម្មសិក្សានេះ មន្ត្រីកម្មសិក្សាដែលជ្រើសរើសចេញពីសិស្ស និស្សិត មិនត្រូវបានផ្តល់ប្រាក់បំណាច់មុខងារ និងប្រាក់វិភាជន៍គ្រួសារនោះទេ ។

រយៈពេលធ្វើកម្មសិក្សា មិនបានគិតក្នុងអតីតភាព សំរាប់តំឡើងថ្នាក់ទេ ប៉ុន្តែគិតក្នុងអតីតភាព សំរាប់សោធននិវត្តន៍ ។

**មាត្រា ៦.-**

មន្ត្រីរាជការមានសិទ្ធិទទួលបៀវត្សមូលដ្ឋានបាន តែក្នុងលក្ខខ័ណ្ឌដូចខាងក្រោម :

១-កំពុងបំពេញសកម្មភាពការងារ

២-កំពុងផ្លាស់ប្តូរកន្លែងធ្វើការនៅក្នុង ឬក្រៅប្រទេស

៣-កំពុងធ្វើដំណើរទៅកាន់មុខតំណែង ឬកំពុងវិលត្រឡប់មកវិញ

៤-កំពុងបំពេញកម្មសិក្សាវិជ្ជាជីវៈ ឬ បច្ចេកទេសតាមតំរូវការរបស់រដ្ឋ

៥-កំពុងបំពេញកម្មសិក្សាជាដំបូង ដើម្បីតាំងស៊ប់ក្នុងក្របខ័ណ្ឌ ។

**មាត្រា ៧.-**

សិទ្ធិទទួលនូវបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ត្រូវគិតចាប់ផ្តើមពីថ្ងៃចូលបំរើការងារជាស្ថាពរ ដែលទទួលស្គាល់ដោយក្រសួងសាមី ហើយត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ ដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ៨.-**

មន្ត្រីរាជការដែលឈប់សំរាកស្របតាមបទប្បញ្ញត្តិនៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងបទប្បញ្ញត្តិផ្សេងៗដែលមានជាធរមាន មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ។

**មាត្រា ៩.-**

បៀវត្សមូលដ្ឋាន ត្រូវផ្តល់ជូនដល់មន្ត្រីរាជការដែលត្រូវចាត់អោយចូលរៀនវគ្គបណ្តុះបណ្តាល បំពាក់បំប៉ន



Downloaded from http://www.khmerlaws.com

វិជ្ជាជីវៈ ឬបច្ចេកទេសតាមតំរូវការរបស់រដ្ឋស្របតាមក្របខ័ណ្ឌរបស់សាមីខ្លួន ។

មាត្រា ១០.-

ការបញ្ឈប់ផ្តល់បៀវត្សមូលដ្ឋាន ត្រូវធ្វើទៅតាមថ្ងៃកំណត់នៃប្រកាស របស់ប្រធានស្ថាប័នក្នុងករណីខាងក្រោមនេះ :

-មន្ត្រីរាជការដែលសុំលាឈប់ពីការងារ ដោយមានការអនុញ្ញាត
-មន្ត្រីរាជការដែលត្រូវបណ្តេញចេញពីមុខតំណែង
-មន្ត្រីរាជការដែលពលី ឬទទួលមរណៈភាព
-មន្ត្រីរាជការដែលអវត្តមានគ្មានការអនុញ្ញាត ឬហួសរយៈពេលកំណត់
-មន្ត្រីរាជការដែលវិលត្រឡប់មកកាន់ការងារវិញហួសរយៈពេលដែលកំណត់ដោយលិខិតបង្គាប់ការ លើកលែងតែករណីស្របច្បាប់ ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
-មន្ត្រីរាជការដែលអវត្តមានហួសកាលកំណត់របស់បេសកកម្ម ឬការឈប់សំរាក លើកលែងតែករណីប្រធានស័ក្តិ ឬដោយជម្ងឺ ដែលមានលិខិតបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬពីសមត្ថកិច្ច សុខាភិបាល
-មន្ត្រីរាជការដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថា ជាទណ្ឌិត

មាត្រា ១១.-

មន្ត្រីរាជការ ដែលត្រូវដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស គ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ចាប់ពីថ្ងៃកំណត់ ដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស ។

មាត្រា ១២.-

មន្ត្រីរាជការ ដែលត្រូវដាក់អោយចូលនិវត្តន៍ គ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន :

-នៅពេលសាមីខ្លួនដល់អាយុចូលនិវត្តន៍
-តាមសំណើសុំរបស់សាមីខ្លួន ចំពោះមន្ត្រីរាជការដែលគ្រប់អតីតភាពការងារសំរាប់ចូលនិវត្តន៍ ។

## ជំពូកទី ២

## ប្រាក់បំណាច់មុខងារ

មាត្រា ១៣.-

ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមទៅលើបៀវត្សមូលដ្ឋានប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការ នៅក្នុងប្រភេទ ក, ខ និង គ ហើយដែលកំពុងបំពេញមុខងារ ក្នុងក្រសួង ស្ថាប័ន។

មាត្រា ១៤.-

ប្រាក់បំណាច់មុខងារ ត្រូវបានបែងចែកជា ០៥កំរិត ទៅតាមរយៈពេល និងបទពិសោធន៍ការងារក្នុងមុខ



Downloaded from http://www.khmerlaws.com

តំណែង នីមួយៗ ដូចខាងក្រោម :

-ការិតទី ៥ សំរាប់បទពិសោធន៍រយៈពេលក្រោម ០៣ឆ្នាំ

-ការិតទី ៤ សំរាប់បទពិសោធន៍រយៈពេលពី ០៣ ទៅ ០៦ឆ្នាំ

-ការិតទី ៣ សំរាប់បទពិសោធន៍រយៈពេលពី ០៦ ទៅ ១០ឆ្នាំ

-ការិតទី ២ សំរាប់បទពិសោធន៍រយៈពេលពី ១០ ទៅ ១៦ឆ្នាំ

-ការិតទី ១ សំរាប់បទពិសោធន៍រយៈពេលលើសពី ១៦ឆ្នាំ

**មាត្រា ១៥.-**

ការផ្លាស់ប្តូរការិត និងការផ្តល់ប្រាក់បំណាច់មុខងារ មិនអាចអនុវត្តន៍ទៅតាមឆ្នាំកំណត់ ដូចមានចែងនៅក្នុង មាត្រា ១៤ ជាស្វ័យប្រវត្តិបានទេ ក៏ប៉ុន្តែត្រូវធ្វើឡើងដោយមានការវាយតំលៃពីប្រធានស្ថាប័ន ។

**មាត្រា ១៦.-**

មន្ត្រីរាជការដែលមានមុខតំណែង ដូចខាងក្រោម ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែង នៅក្នុងតារាងភ្ជាប់ជាមួយនេះ :

| ល.រ | មុខងារ | ការិត ទី៥ | ការិត ទី៤ | ការិត ទី៣ | ការិត ទី២ | ការិត ទី១ |
|---|---|---|---|---|---|---|
| ១ | អគ្គលេខាធិការ រាជរដ្ឋាភិបាល | ៧៨០ ០០០៛ | ៨២៧ ០០០៛ | ៨៧៧ ០០០៛ | ៩៣០ ០០០៛ | ៩៨៦ ០០០៛ |
| ២ | អគ្គលេខាធិការរង រាជរដ្ឋាភិបាល | ៧៦៥ ០០០៛ | ៨១១ ០០០៛ | ៨៦០ ០០០៛ | ៩១២ ០០០៛ | ៩៦៧ ០០០៛ |
| ៣ | អគ្គលេខាធិការ | ៧៥០ ០០០៛ | ៧៩៥ ០០០៛ | ៨៤៣ ០០០៛ | ៨៩៤ ០០០៛ | ៩៤៨ ០០០៛ |
| ៤ | អគ្គនាយក | ៧៣៥ ០០០៛ | ៧៧៩ ០០០៛ | ៨២៦ ០០០៛ | ៨៧៦ ០០០៛ | ៩២៩ ០០០៛ |
| ៥ | អគ្គាធិការ | ៧២០ ០០០៛ | ៧៦៣ ០០០៛ | ៨០៩ ០០០៛ | ៨៥៨ ០០០៛ | ៩១០ ០០០៛ |
| ៦ | អភិបាល ខេត្តក្រុង | ៧០៥ ០០០៛ | ៧៤៧ ០០០៛ | ៧៩២ ០០០៛ | ៨៤០ ០០០៛ | ៨៩១ ០០០៛ |
| ៧ | សាកលវិទ្យាធិការ | ៦៩០ ០០០៛ | ៧៣២ ០០០៛ | ៧៧៦ ០០០៛ | ៨២៣ ០០០៛ | ៨៧៣ ០០០៛ |
| ៨ | សាស្ត្រាចារ្យមហាបរិញ្ញា | ៦៧៥ ០០០៛ | ៧១៦ ០០០៛ | ៧៥៩ ០០០៛ | ៨០៥ ០០០៛ | ៨៥៣ ០០០៛ |
| ៩ | អគ្គលេខាធិការរង | ៦៦០ ០០០៛ | ៧០០ ០០០៛ | ៧៤២ ០០០៛ | ៧៨៧ ០០០៛ | ៨៣៤ ០០០៛ |
| ១០ | អគ្គនាយករង | ៦៤៥ ០០០៛ | ៦៨៤ ០០០៛ | ៧២៥ ០០០៛ | ៧៦៩ ០០០៛ | ៨១៥ ០០០៛ |
| ១១ | អគ្គាធិការរង | ៦៣០ ០០០៛ | ៦៦៨ ០០០៛ | ៧០៨ ០០០៛ | ៧៥១ ០០០៛ | ៧៩៦ ០០០៛ |
| ១២ | សាកលវិទ្យាធិការរង | ៦៣០ ០០០៛ | ៦៦៨ ០០០៛ | ៧០៨ ០០០៛ | ៧៥១ ០០០៛ | ៧៩៦ ០០០៛ |

**មាត្រា ១៧.-**

ប្រាក់បំណាច់មុខងារប្រចាំខែ របស់មន្ត្រីរដ្ឋបាលទូទៅ ត្រូវផ្តល់ជូនចំពោះមន្ត្រីរាជការ ដែលកំពុងបំពេញ មុខងារ ក្នុងមុខតំណែង ដែលមានចែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ដូចខាងក្រោមនេះ :

| ល.រ | មុខងារ | ការិត ទី៥ | ការិត ទី៤ | ការិត ទី៣ | ការិត ទី២ | ការិត ទី១ |
|---|---|---|---|---|---|---|

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ១ | ប្រធាន នាយកដ្ឋាន | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ២ | អធិការ | ៥៧ ៥០០៛ | ៦២ ១០០៛ | ៦៧ ១០០៛ | ៧២ ៥០០៛ | ៧៨ ៣០០៛ |
| ៣ | អនុប្រធាន នាយកដ្ឋាន | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៤ | អធិការរង | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៥ | ប្រធានមន្ទីរខេត្តក្រុង | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ៦ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៧ | ប្រធានការិយាល័យ ថ្នាក់កណ្តាល | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៨ | អនុប្រធានមន្ទីរខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៩ | អនុប្រធានការិយាល័យ ថ្នាក់កណ្តាល | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ១០ | ប្រធានការិយាល័យ មន្ទីរខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១១ | អនុប្រធានការិយាល័យ មន្ទីរខេត្តក្រុង | ៣៥ ០០០៛ | ៣៧ ៨០០៛ | ៤០ ៨០០៛ | ៤៤ ១០០៛ | ៤៧ ៦០០៛ |
| ១២ | ប្រធានការិយាល័យ ស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៣ | មន្ត្រីក្រមការ | ៣០ ០០០៛ | ៣២ ៤០០៛ | ៣៥ ០០០៛ | ៣៧ ៨០០៛ | ៤០ ៨០០៛ |
| ១៤ | អនុប្រធានការិយាល័យ ស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៥ | លេខាធិការដើមខ្សែ | ២២ ៥០០៛ | ២៤ ៣០០៛ | ២៦ ៣០០៛ | ២៨ ៤០០៛ | ៣០ ៧០០៛ |
| ១៦ | លេខាធិការ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |

មាត្រា ១៨.-

ប្រាក់បំណាច់មុខងារប្រចាំខែ របស់មន្ត្រីរដ្ឋបាលដែនដី ត្រូវផ្តល់ជូនចំពោះមន្ត្រីរាជការក្រសួងមហាផ្ទៃ ដែលកំពុងបំពេញមុខងារក្នុងមុខតំណែង ដែលមានចែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | អភិបាលរង ខេត្តក្រុង | ៦០ ០០០៛ | ៦១ ៩០០៛ | ៦៦ ៩០០៛ | ៧២ ៣០០៛ | ៧៨ ១០០៛ |
| ២ | អភិបាល ស្រុកខ័ណ្ឌ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ៣ | នាយខុទ្ទកាល័យ សាលាខេត្តក្រុង | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ៤ | អគ្គលេខាធិការ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៥ | ប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៦ | ប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៧ | នាយរងខុទ្ទកាល័យ សាលាខេត្តក្រុង | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៨ | អភិបាលរង ស្រុកខ័ណ្ឌ | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ៩ | អគ្គលេខាធិការរង សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១០ | អនុប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១១ | អនុប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |
| ១២ | ប្រធានការិយាល័យ សាលាខេត្តក្រុង | ៣៧ ៥០០៛ | ៤០ ៥០០៛ | ៤៣ ៨០០៛ | ៤៧ ៣០០៛ | ៥១ ១០០៛ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ១៣ | ប្រធាន មន្ទីរ សាលាស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៤ | អនុប្រធានការិយាល័យ សាលាខេត្តក្រុង | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៥ | ប្រធានការិយាល័យ សាលាស្រុកខ័ណ្ឌ | ៣២ ៥០០៛ | ៣៥ ១០០៛ | ៣៧ ៩០០៛ | ៤០ ៩០០៛ | ៤៤ ២០០៛ |
| ១៦ | អនុប្រធាន មន្ទីរ សាលាស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៧ | អនុប្រធាន ការិយាល័យ សាលាស្រុកខ័ណ្ឌ | ២៥ ០០០៛ | ២៧ ០០០៛ | ២៩ ២០០៛ | ៣១ ៥០០៛ | ៣៤ ០០០៛ |
| ១៨ | លេខាធិការ ថ្នាក់ខេត្តក្រុង ស្រុកខ័ណ្ឌ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |
| ១៩ | ស្មៀនឃុំសង្កាត់ | ២០ ០០០៛ | ២១ ៦០០៛ | ២៣ ៣០០៛ | ២៥ ២០០៛ | ២៧ ២០០៛ |
| ២០ | ប្រធានពន្ធនាគារកណ្ដាល | ៧៦ ៧០០៛ | ៨២ ៨០០៛ | ៨៩ ៤០០៛ | ៩៦ ៦០០៛ | ១០៤ ៣០០៛ |
| ២១ | អនុប្រធានពន្ធនាគារកណ្ដាល | ៧៤ ២០០៛ | ៨០ ១០០៛ | ៨៦ ៥០០៛ | ៩៣ ៤០០៛ | ១០០ ៩០០៛ |
| ២២ | ប្រធានពន្ធនាគារខេត្តក្រុង | ៧១ ៧០០៛ | ៧៧ ៤០០៛ | ៨៣ ៦០០៛ | ៩០ ៣០០៛ | ៩៧ ៥០០៛ |
| ២៣ | អនុប្រធានពន្ធនាគារខេត្តក្រុង | ៦៩ ២០០៛ | ៧៤ ៧០០៛ | ៨០ ៧០០៛ | ៨៧ ២០០៛ | ៩៤ ២០០៛ |
| ២៤ | នាយផ្នែករដ្ឋបាលពន្ធនាគារ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ២៥ | នាយរង ផ្នែករដ្ឋបាលពន្ធនាគារ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ | ៦៦ ១០០៛ | ៧១ ៤០០៛ |
| ២៦ | អ្នកគ្រប់គ្រងអ្នកទោសក្នុងពន្ធនាគារ | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |

មាត្រា ១៩.-

ប្រាក់បំណាច់មុខងារប្រចាំខែ ក្នុងវិស័យអប់រំ មានដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរស មហាវិទ្យាល័យ | ៨០ ០០០៛ | ៨៤ ០០០៛ | ៨៨ ២០០៛ | ៩២ ៦០០៛ | ៩៧ ២០០៛ |
| ២ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៧៨ ០០០៛ | ៨១ ៩០០៛ | ៨៦ ០០០៛ | ៩០ ៣០០៛ | ៩៤ ៨០០៛ |
| ៣ | សាស្ត្រាចារ្យ ឧត្ដមសិក្សា | ៧៧ ០០០៛ | ៨០ ៩០០៛ | ៨៥ ០០០៛ | ៨៩ ៣០០៛ | ៩៣ ៨០០៛ |
| ៤ | នាយក វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៥ | នាយក វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៦ | នាយក វិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេស | ៧៦ ០០០៛ | ៧៩ ៨០០៛ | ៨៣ ៨០០៛ | ៨៨ ០០០៛ | ៩២ ៤០០៛ |
| ៧ | គ្រូបង្រៀន ឧត្ដមសិក្សា | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ | ៨៧ ០០០៛ | ៩១ ៤០០៛ |
| ៨ | នាយករង វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ៩ | នាយករង វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១០ | នាយករង វិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេស | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១១ | អធិការ មធ្យមសិក្សា | ៧៤ ០០០៛ | ៧៧ ៧០០៛ | ៨១ ៦០០៛ | ៨៥ ៧០០៛ | ៩០ ០០០៛ |
| ១២ | នាយក វិទ្យាល័យ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៣ | នាយក មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៤ | នាយក សាលាគរុកោសល្យខេត្តក្រុង | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៥ | នាយក មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ១៦ | នាយក សាលាមធ្យមសិក្សាបច្ចេកទេសឬស្សីកែវ | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៧ | នាយក សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៨ | នាយក សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមធ្យម | ៧៣ ០០០៛ | ៧៦ ៧០០៛ | ៨០ ៥០០៛ | ៨៤ ៥០០៛ | ៨៨ ៧០០៛ |
| ១៩ | នាយករង វិទ្យាល័យ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២០ | នាយករង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២១ | នាយករង សាលាគរុកោសល្យខេត្តក្រុង | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២២ | នាយករង មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៣ | នាយករង សាលាមធ្យមសិក្សាបច្ចេកទេសឬស្សីកែវ | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៤ | នាយករង សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៥ | នាយករង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមធ្យម | ៧២ ០០០៛ | ៧៥ ៦០០៛ | ៧៩ ៤០០៛ | ៨៣ ៤០០៛ | ៨៧ ៦០០៛ |
| ២៦ | គ្រូបង្រៀន មធ្យមសិក្សា ទុតិយភូមិ | ៧១ ០០០៛ | ៧៤ ៦០០៛ | ៧៨ ៣០០៛ | ៨២ ២០០៛ | ៨៦ ៣០០៛ |
| ២៧ | អធិការ បឋមសិក្សា | ៦៩ ០០០៛ | ៧២ ៥០០៛ | ៧៦ ១០០៛ | ៧៩ ៩០០៛ | ៨៣ ៩០០៛ |
| ២៨ | នាយក អនុវិទ្យាល័យ | ៦៨ ០០០៛ | ៧១ ៤០០៛ | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ |
| ២៩ | នាយក មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៦៨ ០០០៛ | ៧១ ៤០០៛ | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ |
| ៣០ | នាយករង អនុវិទ្យាល័យ | ៦៧ ០០០៛ | ៧០ ៤០០៛ | ៧៣ ៩០០៛ | ៧៧ ៦០០៛ | ៨១ ៥០០៛ |
| ៣១ | នាយករង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៦៧ ០០០៛ | ៧០ ៤០០៛ | ៧៣ ៩០០៛ | ៧៧ ៦០០៛ | ៨១ ៥០០៛ |
| ៣២ | គ្រូបង្រៀន មធ្យមសិក្សា បឋមភូមិ | ៦៦ ០០០៛ | ៦៩ ៣០០៛ | ៧២ ៨០០៛ | ៧៦ ៥០០៛ | ៨០ ៣០០៛ |
| ៣៣ | នាយក សាលាបឋមសិក្សា | ៦៤ ០០០៛ | ៦៧ ២០០៛ | ៧០ ៦០០៛ | ៧៤ ១០០៛ | ៧៧ ៨០០៛ |
| ៣៤ | នាយក សាលាមត្តេយ្យ | ៦៤ ០០០៛ | ៦៧ ២០០៛ | ៧០ ៦០០៛ | ៧៤ ១០០៛ | ៧៧ ៨០០៛ |
| ៣៥ | នាយករង សាលាបឋមសិក្សា | ៦៣ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ | ៧៦ ៧០០៛ |
| ៣៦ | នាយករង សាលាមត្តេយ្យ | ៦៣ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ | ៧៦ ៧០០៛ |
| ៣៧ | គ្រូបង្រៀន បឋមសិក្សា_មត្តេយ្យសិក្សា | ៦២ ០០០៛ | ៦៥ ១០០៛ | ៦៨ ៤០០៛ | ៧១ ៨០០៛ | ៧៥ ៤០០៛ |
| ៣៨ | គ្រូបង្រៀន កំរិតបឋម | ៦០ ០០០៛ | ៦៣ ០០០៛ | ៦៦ ២០០៛ | ៦៩ ៥០០៛ | ៧៣ ០០០៛ |

មាត្រា ២០.-

ប្រាក់បំណាច់មុខងារប្រចាំខែ ក្នុងវិស័យសុខាភិបាល មានដូចខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរស មហាវិទ្យាល័យ | ៨០ ០០០៛ | ៨៤ ០០០៛ | ៨៨ ២០០៛ | ៩២ ៦០០៛ | ៩៧ ២០០៛ |
| ២ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៧៨ ០០០៛ | ៨១ ៩០០៛ | ៨៦ ០០០៛ | ៩០ ៣០០៛ | ៩៤ ៨០០៛ |
| ៣ | នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រថ្នាក់កណ្តាល | ៧៨ ០០០៛ | ៨១ ៩០០៛ | ៨៦ ០០០៛ | ៩០ ៣០០៛ | ៩៤ ៨០០៛ |
| ៤ | នាយករង សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រថ្នាក់កណ្តាល | ៧៥ ០០០៛ | ៧៨ ៨០០៛ | ៨២ ៨០០៛ | ៨៧ ០០០៛ | ៩១ ៤០០៛ |
| ៥ | នាយក មន្ទីរពេទ្យជាតិ | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ៦ | នាយក មជ្ឈមណ្ឌលជាតិ | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |

Downloaded from http://www.khmerlaws.com

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | នាយក វិទ្យាស្ថានជាតិ | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ៨ | នាយក មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ៩ | នាយក ឃ្លាំងឱសថកណ្តាល | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ១០ | នាយករង មន្ទីរពេទ្យជាតិ | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១១ | នាយករង មជ្ឈមណ្ឌលជាតិ | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១២ | នាយករង វិទ្យាស្ថានជាតិ | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១៣ | នាយករង មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១៤ | នាយករង ឃ្លាំងឱសថកណ្តាល | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ១៥ | ប្រធានការិយាល័យ ស្រុកប្រតិបត្តិ | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |
| ១៦ | អនុប្រធានការិយាល័យ ស្រុកប្រតិបត្តិ | ៤៧ ៥០០៛ | ៥១ ៣០០៛ | ៥៥ ៤០០៛ | ៥៩ ៨០០៛ | ៦៤ ៦០០៛ |
| ១៧ | ប្រធាន មន្ទីរពេទ្យបង្អែក | ៤៧ ៥០០៛ | ៥១ ៣០០៛ | ៥៥ ៤០០៛ | ៥៩ ៨០០៛ | ៦៤ ៦០០៛ |
| ១៨ | អនុប្រធាន មន្ទីរពេទ្យបង្អែក | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ១៩ | ប្រធាន មណ្ឌលសុខភាព | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ២០ | អនុប្រធាន មណ្ឌលសុខភាព | ៤២ ៥០០៛ | ៤៥ ៩០០៛ | ៤៩ ៦០០៛ | ៥៣ ៦០០៛ | ៥៧ ៩០០៛ |
| ២១ | គ្រូពេទ្យ ឯកទេស | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ២២ | គ្រូពេទ្យ.អនុបណ្ឌិត | ៦៥ ០០០៛ | ៧០ ២០០៛ | ៧៥ ៨០០៛ | ៨១ ៩០០៛ | ៨៨ ៥០០៛ |
| ២៣ | ឱសថបណ្ឌិត | ៦០ ០០០៛ | ៦៤ ៨០០៛ | ៧០ ០០០៛ | ៧៥ ៦០០៛ | ៨១ ៧០០៛ |
| ២៤ | គ្រូពេទ្យ ការពារ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ២៥ | ឱសថការី ការពារ | ៥៥ ០០០៛ | ៥៩ ៤០០៛ | ៦៤ ២០០៛ | ៦៩ ៣០០៛ | ៧៤ ៩០០៛ |
| ២៦ | គ្រូពេទ្យ ព្យាបាល | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |
| ២៧ | ឱសថការី ព្យាបាល | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |
| ២៨ | ទន្តបណ្ឌិត | ៥០ ០០០៛ | ៥៤ ០០០៛ | ៥៨ ៣០០៛ | ៦៣ ០០០៛ | ៦៨ ១០០៛ |
| ២៩ | គ្រូពេទ្យ មធ្យម | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៣០ | ទន្តពេទ្យ មធ្យម | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៣១ | ឱសថការី មធ្យម | ៤៥ ០០០៛ | ៤៨ ៦០០៛ | ៥២ ៥០០៛ | ៥៦ ៧០០៛ | ៦១ ២០០៛ |
| ៣២ | ឆ្មបមធ្យម | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៣៣ | គិលានុបដ្ឋាក មធ្យម | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៣៤ | អ្នកព្យាបាលដោយចលនា មធ្យម | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |
| ៣៥ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍ មធ្យម | ៤០ ០០០៛ | ៤៣ ២០០៛ | ៤៦ ៧០០៛ | ៥០ ៤០០៛ | ៥៤ ៤០០៛ |

មាត្រា ២១.-

មន្ត្រីរាជការដែលស្ថិតនៅក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងនោះ ។

មន្ត្រីរាជការដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតអោយជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយទេ ។

Downloaded from http://www.khmerlaws.com

មាត្រា ២២.-

ការកែប្រែប្រាក់បំណាច់មុខងារ ត្រូវធ្វើឡើង ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## ប្រាក់ហានិភ័យ

មាត្រា ២៣.-

ប្រាក់ហានិភ័យ គឺជាប្រាក់ប្រចាំខែសំរាប់ផ្តល់ជូនដល់មន្ត្រីរាជការទាំងឡាយណា ដែលត្រូវចាត់ឱ្យទៅបំរើការងារ ឬបំរើការងារ នៅក្នុងមុខងារ ឬទីកន្លែង ដែលមានគ្រោះថ្នាក់ ជំងឺឆ្លង ការងារប៉ះពាល់សុខភាព ការងារដែលបណ្តាលឱ្យខូចសុខភាព ដូចជា កន្លែងក្តៅ សើម មានធូលីច្រើន ឬពុល ចំហាយជាតិពុល ឬជាតិគីមី សំលេងខ្ទរខ្លាំង ក្លិនស្អុយ និងតំបន់គ្រុនចាញ់។

មាត្រា ២៤.-

ប្រាក់ ហានិភ័យ មានពីរ គឺៈ

១-ប្រាក់ប៉ះពាល់សុខភាព

២-ប្រាក់តំបន់

មុខងារដែលប៉ះពាល់សុខភាព និងតំបន់ហានិភ័យ ព្រមទាំងប្រាក់ហានិភ័យ នឹងត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក។

## ជំពូកទី ៤

## ប្រាក់វិភាជន៍គ្រួសារ

មាត្រា ២៥.-

ប្រាក់វិភាជន៍គ្រួសារ គឺជាប្រាក់ប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការជាមេគ្រួសារ សំរាប់ប្រពន្ធ កូន និងកូនចិញ្ចឹមស្របច្បាប់ នៅក្នុងបន្ទុក ។

ប្រាក់វិភាជន៍សំរាប់កូនអាចបន្តផ្តល់ជូន រហូតដល់អាយុ ២១ឆ្នាំ ក្នុងករណីមានលិខិតបញ្ជាក់ការសិក្សា ។

មាត្រា ២៦.-

ប្រាក់វិភាជន៍គ្រួសារ ត្រូវផ្តល់ជូនមន្ត្រីរាជការនៅក្នុងគ្រប់ករណីដែលសាមីខ្លួននៅមានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ។

មន្ត្រីរាជការដែលជាមេគ្រួសារ ត្រូវទទួលខុសត្រូវចំពោះពត៌មានស្តីពីស្ថានភាពគ្រួសារទាក់ទងនឹងប្រាក់ វិភាជន៍គ្រួសារ ។



Downloaded from http://www.khmerlaws.com

មាត្រា ២៧.-

ប្រាក់វិភាជន៍គ្រួសារប្រចាំខែត្រូវផ្តល់ជូន ដូចខាងក្រោម :

| ប្រាក់វិភាជន៍គ្រួសារ | ចំនួនទឹកប្រាក់ |
|---|---|
| ប្រពន្ធ | ៣ ០០០ រៀល |
| កូន | ២ ៥០០ រៀល |

មាត្រា ២៨.-

ការកែប្រែប្រាក់វិភាជន៍គ្រួសារ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

មាត្រា ២៩.-

មន្ត្រីរាជការក្នុងក្របខ័ណ្ឌ **ក ខ គ** ដែលពុំមានមុខតំណែងចែងក្នុងព្រះរាជក្រឹត្យនេះ នឹងត្រូវទទួលប្រាក់បំណាច់មុខងារសមមូលនឹងប្រាក់បំណាច់មុខងារ របស់មន្ត្រីរដ្ឋបាលទូទៅ ដែលមានចែងក្នុងមាត្រាទី ១៧ ។

មាត្រា ៣០.-

ប្រាក់ប៉ះពាល់សុខភាព និងប្រាក់តំបន់ ដែលកំពុងអនុវត្តបច្ចុប្បន្ន នៅមានសុពលភាព រហូតដល់ពេលដែលអនុក្រឹត្យថ្មីស្តីពី មុខងារដែលប៉ះពាល់សុខភាព និងតំបន់ហានិភ័យ ព្រមទាំងប្រាក់ហានិភ័យ ត្រូវបានដាក់ឱ្យចូលជាធរមានជំនួស ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

មាត្រា ៣១.-

រាល់បទបញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣២.-

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

Downloaded from http://www.khmerlaws.com

មាត្រា ៣៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

នស.០១.១២.០០៤៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**ហត្ថលេខា**

**សុខ អាន**

លេខ: ៩៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

Downloaded from http://www.khmerlaws.com